ក-270

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយនិពន្ធខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ឃុនវិចិត្រធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកនិពន្ធខាងសាសនាៈ លោកអាចារ្យ កៅ-ស៊ុម អ្នកត្រួតត្រា
សិស្សនៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

| ផ្នែកអក្សរសាស្ត្រ | | ទំព័រ |
|---|---|---|
| លោកអាចារ្យ កៅ-ស៊ុម . . . . . | វិទ្យុគន្ធទេសនា កណ្ឌទី ១៥ . . . . . . . . | ១ |
| លោកអាចារ្យ ឈឹម-ស៊ុំ . . . . . | " " ១៦ . . . . . . . . | ១៤ |
| ព្រះមហា សោម-ឡុច . . . . . | " " ១៧ . . . . . . . . | ២៩ |
| លោក សង់-ហង់វីហ្សប . . . . | អំពីរបៀបជីវិតនៃសត្វល្អិតៗ . . . . . . . . | ៣៦ |
| អ្នកឧកញ៉ាពេស្តាវិទិត្ថិយ កែវ-ហង្ស | ប្រលោមចិត្ត (ពាក្យកាព្យ) . . . . . . . . . | ៥៨ |
| អ្នកឧកញ៉ាវង្សាសារពេជ្ញ (នង) . . | លោកនយោបាយ ពាក្យកាព្យ (តមក) . . . . | ៧៩ |
| ឃុនវិចិត្រធមន្ត្រី ញ៉ុក-ថែម . . . . . | ពង្សាវតារប្រទេសចិន . . . . . . . . . . . | ១០៥ |
| ផ្នែកសាសនា | | |
| ដំណឹងអំពីក្រសួងធម្មការ . . . . . | បញ្ជីរាយនាមមន្ត្រីសង្ឃនិងលោកអធិការ ដែលទើបតាំងឡើងថ្មី . . . . . . . . . . . . . | ១២៤ |
| " " . . . . . . | បុណ្យបញ្ចុះសីមានៅវត្តនានា . . . . . . . | ១២៩ |
| ឃុនវិចិត្រធមន្ត្រី ញ៉ុក-ថែម . . . . | ប្រវត្តិសង្ខេបបញ្ចមសង្គាយនា (តមកនឹងចប់). | ១៣៣ |
| " " . . . . . . | ប្រវត្តិព្រះមហាកច្ចាយនត្ថេរ . . . . . . . . | ១៣៦ |
| លោកអាចារ្យ ឈឹម-ស៊ុំ . . . . | ពុទ្ធឃោសប្បវត្តិ . . . . . . . . . . . . | ១៤៣ |

...ទី ១៥ លេខ ១-២-៣ ប្រចាំខែយ៉ាំងវីយេរ-ហ្វេវ្រីយេរ-ម៉ារ្ស ១៩៤៣ ។

ថ្លៃជាវ ១ ឆ្នាំ ១០:០០ ។

BIBLIOTHÈQUE
NATIONALE
DU CAMBODGE
P. K. 1
1943 (1-3)

K-270-

វិទ្យុធម្មទេសនា កណ្ឌទី ១៥

# លោកគ្រូអាចារ្យ កៅ-ស៊ុម

អ្នកគ្រូគ្រោសំស្សាលាបាលីជាន់ខ្ពស់

សំដែង កាលពីថ្ងៃសុក្រ ១៤ រោចខែជេស្ឋ ឆ្នាំមមីចត្វាស័កពុទ្ធសករាជ ២៤៨៥

(១២ យូអាំង ១៩៤២)

## ធម្មរតនត្តយស្ស

ខ្ញុំសូមនមស្សការ ថ្វាយបង្គំព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ដែលជាទីពឹងដ៏ប្រសើរខ្ពង់ខ្ពស់ របស់សត្វលោកជារទេះ សម្រាប់ដឹកនាំសត្វទៅកាន់ព្រះនិព្វាន ដោយសេចក្តីគោរព ។

តអំពីបទនមស្សការនេះទៅ សូមអញ្ជើញពួកទេពតាទាំងឡាយ ចូរមូលមកអំពីទិសផ្សេងៗ ស្តាប់ធម៌ទេសនារបស់យើង ហើយសូមខំព្យាយាមប្រឹងប្រែងរក្សាព្រះពុទ្ធសាសនាជាមួយនឹងយើង ។

បណ្តាសប្បុរសទាំងឡាយឯណា ដែលមានព្រះធម៌ជាទីពឹងដ៏ប្រសើរ បានស្លាប់បង់បាបជ្រះស្រឡះហើយ សប្បុរសទាំងនោះដែលបានយកកំណើតកើតជាមនុស្សពិត ក៏សូមអញ្ជើញមកអំពីទិសផ្សេងៗ ហើយសូមសេពគប់ប្រសព្វជាមួយនឹងយើង ជាមិត្រស្នេហា ស្តាប់ធម៌ទេសនារបស់យើង ក្នុងវេលានេះឯង ។

លំដាប់អំពីនេះទៅ សូមលើកយកបទ "មិត្តកថា" មកអធិប្បាយតាមការៈដែលត្រូវសំដែងផ្សាយតាមវិទ្យុនេះ ដើម្បីជាសណ្តាប់ផល

អស់លោកសប្បុរសទាំងឡាយ ដែលប្រុងស្តាប់ហើយនិងប្រតិបត្តិឲ្យបានសមគួរតាមពុទ្ធឱវាទ ទើបបានសម្រេចប្រយោជន៍សេចក្តីសុខចំរើនក្នុងលោកនេះ និងលោកខាងមុខ ដោយផលានិសង្សដែលបានប្រព្រឹត្តត្រឹមត្រូវនេះ ។

មុននឹងសំដែងអំពីបទមាតិកាថានេះ សូមនាំយកពុទ្ធភាសិតដែលសំដែងអំពីរបស់នៅឆ្ងាយអំពីគ្នា ៤ យ៉ាងមកផ្តើមជាធម្មហេតុសិន ដោយពាក្យព្រះបាលីថា:

ឥមានិ ខោ ភិក្ខវេ ចត្តារិ សុវិទូរវិទូរានិ

សេចក្តីថា: ម្នាលភិក្ខុទាំងឡាយ របស់ដែលនៅឆ្ងាយហើយសែនឆ្ងាយអំពីគ្នាមាន ៤ យ៉ាង:

១- អាកាសនិងផែនដី

២- ត្រើយសមុទ្រខាងអាយនិងត្រើយសមុទ្រខាងនាយ

៣- ទិសបូព៌ាខាងកើតនិងទិសបស្ចិមខាងលិច

៤- ធម៌របស់សប្បុរសនិងធម៌របស់អសប្បុរស ។

បណ្តារបស់ទាំង ៤ យ៉ាង ដែលបានរៀបរាប់មកនេះ ជារបស់នៅឆ្ងាយអំពីគ្នា ពុំដែលបានជួបប្រទះគ្នាដល់ម្តងសោះឡើយ ព្រមទាំងពុំដឹងសេចក្តីសុខទុក្ខ ឬដំណើរកិច្ចការគ្នាទៅវិញទៅមក និងទទួលអំណរសេចក្តីរុងរឿងអ្វីមួយដល់គ្នាពុំកើត, ដូចអាកាសឬមេឃដែលខ្ពស់ស្រឡះ

ផុតអំពីផែនដីឥតមានបំណាំងបង្អុរភ្លៀងឲ្យធ្លាក់ចុះមកលើផែនដី ហើយហូរព្រោះបំផ្លាញផែនដីឲ្យដាច់ធ្លាក់ចុះទៅក្នុងមហាសមុទ្រ ឬទន្លេស្ទឹង-ព្រែកនោះឡើយ ឯផែនដីក៏មិនអាចទំនងស្រែកប្រាប់ទៅអាកាសថា: "នៃ អា-កាស! ឯងកុំបង្អុរភ្លៀងឲ្យធ្លាក់ចុះមកលើអញ ហើយហូរព្រោះនាំឲ្យអញចូលទៅក្នុងមហាសមុទ្រ ឬស្រែកប្រាប់ថា អញវេទនាណាស់ ត្រជាក់ណាស់ ឯទន្លេ-ស្ទឹង-ព្រែក, រុក្ខជាតិ លតាវល្លិជាដើម ដែលអាស្រ័យទីងអញសោត ក៏លិចលង់ស្លាប់អស់ហើយ ឯងឈប់កុំភ្លៀងមកជួបេះពុំបានដែរ"; ពុំនោះសោត កាលបើផែនដីទទួលកំដៅព្រះអាទិត្យក្តៅបែកក្រ-ហែងក្នុងរដូវវាំងប្រាំង ក៏មិនអាចអង្វរអាកាស សូមឲ្យភ្លៀងធ្លាក់មកជួយការពារកំដៅព្រះអាទិត្យបានឡើយ យ៉ាងនេះបានឈ្មោះថាអាកាសនឹងផែនដីប្រែស្រ័យយកគ្នាជាមិត្តសំឡាញ់ឲ្យសមតាមសេចក្តីប្រាថ្នារបស់ខ្លួនពុំកើត ។

ដែលថាត្រើយសមុទ្រខាងកាយនឹងត្រើយសមុទ្រខាងនាយ ជារបស់នៅឆ្ងាយអំពីគ្នានោះ ក៏ដូចអាកាសនឹងផែនដីដែរ គឺថានឹងប្រាប់ដំណឹងទៅវិញទៅមកនឹងគ្នាថា "ត្រើយសមុទ្រខាងនេះ មានភ្នំធំតូចខ្ពស់ទាប ដើមឈើលតាវល្លិធំតូចវែងខ្លីមានពណ៌សណ្ឋានខែ្ទន់ព្រោយយ៉ាងនេះ យ៉ាងនោះ ឬត្រីតូចធំសម្បូរនៅកៀនកោះនេះប៉ុណ្ណេះៗ មានចំនួន

ដូចផុះកាយជាផ្លូវតាមមាត់សមុទ្រប៉ុណ្ណោះៗ រលកបក់បោកមកក្នុង ១ ថ្ងៃប៉ុណ្ណោះៗ" ពុំបាននឹងយកគ្នាជាមិត្តសំឡាញ់ជាទីពឹងពាក់ក៏មិនកើត ។

ដែលថា ទិសបូព៌ាខាងកើត និងទិសបស្ចិមខាងលិច ជារបស់នៅឆ្ងាយអំពីគ្នានោះ គឺមិនជាអ្នកណានាជួយការពារឬប្រាប់ដំណឹងចំពោះហេតុអ្វីមួយ ដែលកើតឡើងដល់គ្នាបានដល់ម្ដងឡើយ សូម្បីតែព្រះអាទិត្យព្រះចន្ទដែលរះឡើងអំពីទិសបូព៌ា ក៏ពុំដែលប្រាប់ទៅទិសបស្ចិមថា: "ព្រះអាទិត្យ ព្រះចន្ទរះឡើងហើយ ពីពេលប៉ុណ្ណោះៗ ក្ដៅយ៉ាងនេះ ត្រជាក់យ៉ាងនេះ មានទំហំវង់មូលប៉ុណ្ណោះៗ ទុកណាជាព្រះអាទិត្យព្រះចន្ទដើរទៅដល់ទិសខាងលិចហើយ ទិសបស្ចិមក៏មិនដែលប្រាប់ត្រឡប់ទៅទិសខាងកើតថា ព្រះអាទិត្យព្រះចន្ទមកដល់កន្លែងខ្ញុំពេលប៉ុណ្ណោះហើយក្ដៅយ៉ាងនេះ ត្រជាក់យ៉ាងនេះ មានទំហំវង់មូលប៉ុណ្ណោះៗ លិចបាត់ទៅពេលប៉ុណ្ណោះដែរ" នឹងប្រស្រ័យយកជាមិត្តសំឡាញ់ឲ្យជួយសម្រេចកិច្ចណាមួយពុំបានឡើយ ។

ដែលថា ធម៌របស់សប្បុរស និងធម៌របស់អសប្បុរស ជាធម៌ឆ្ងាយអំពីគ្នានោះ គួរជ្រាបថា: លោកដែលជាសប្បុរសអ្នកមានប្រាជ្ញា បានប្រកបដោយធម៌ទាំង ៧ យ៉ាង មានសទ្ធាការជឿកម្មនិងផលរបស់កម្ម ជឿហេតុដែលគួរជឿជាដើម លោកមិនបានធ្វើអំពើអាក្រក់ដោយ កាយ-វាចា-ចិត្តដែលជាអំពើនាំឲ្យមានទោសទុក្ខក្នុងនាលោកនេះ និងបរលោក

ខាងមុខមិនដែលចូលទៅសេពគប់សមាគមឲ្យប្រឡូកប្រឡំដោយពុំដឹងជាអសប្បុរសនោះឡើយ ព្រោះថា ជនជាអសប្បុរសតែងប្រព្រឹត្តធ្វើអំពើអាក្រក់ដ៏អោះមុត លោកទុកដូចជាពស់វែកដែលមានពិសដ៏ខ្លាំងក្លា អាចចឹកបុគ្គលដទៃឥតត្រាប្រណីថានេះមនុស្សប្រុសគួរទាំងពួនឡើយ ក៏នឹងធ្វើសេចក្តីភ័យឲ្យកើតឡើង ដរាបដល់អន្តរាយជីវិតពុំខាន ។

ហេតុនេះឯង ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងថា : "ចជ ទុជ្ជនសំសគ្គំ ភជ សាធុ សមាគមំ" បុគ្គលត្រូវតែលះលែងកុំសេពគប់សមាគមឲ្យប្រឡូកប្រឡំ ទាំងពុំដឹងជាអសប្បុរសនោះឡើយ ត្រូវចូលទៅសេពគប់សមាគមនឹងជនជាសប្បុរស យកជាមិត្តស្និទ្ធស្នាល ប្រកបនូវប្រយោជន៍របស់ខ្លួនចុះ ទើបនាំខ្លួនឲ្យកើតសេចក្តីសុខ-ចំរើនគ្រប់ប្រការ ។

បើតាមសេចក្តីពិតនោះ ត្រូវតែសេពគប់នឹងមនុស្សដែលខ្លាចមិនហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់ផ្សេងៗ ដែលលោកអ្នកប្រាជ្ញទាំងឡាយតែងកាន់សរសើរ គឺមនុស្សណាដែលប្រព្រឹត្តធ្វើអំពើដ៏លាមកអាក្រក់ ហើយមានគំនិតគិតឃើញភ័យ ដែលកើតមកអំពីសេចក្តីទុក្ខទាល់ក្រលំ-ផាក, ទាំងដល់ផលរបស់សេចក្តីព្យាយាមខំប្រឹងប្រែងទាំងដល់គាថ៌រៈរបស់សេដ្ឋីគហបតី(១) ទាំងដល់អាហារដែលស្វែងរកមកចិញ្ចឹមជីវិត ទាំង

---

១ ត្រូវការតែប្រាជ្ញាភោគសម្បទ, ចូលចិត្តព្រិះរិះរកផ្លូវបញ្ញា តាំងចិត្តខ្ជាប់ខ្ជួនចំពោះទៅរកសិល្បសាស្ត្រ, ចូលចិត្តប្រកាន់មាំធ្វើការងារ, មានការងារធ្វើហើយប្រសើរជាទីបំផុត ។

ត្រួតត្រាមើលកឬសទន់ដើមទុន កើតឡើងចំពោះមុខទុកជាផលប្រយោជន៍ ព្រមទាំងត្រិះរិះដល់គុណបុព្វបុរស ដែលលោកបានទំនុកបំរុងរក្សាជីវិត នឹងវង្សត្រកូលយ៉ាងណា មិនត្រូវសេពគប់នឹងមនុស្សខ្ជិលច្រអូសដែល មានសន្តានចិត្តដ៏ថោកទាបឡើយ ត្រូវសេពគប់នឹងមនុស្សអ្នកមាន ព្យាយាមជាគូគ្នា នឹងត្រូវធ្វើចិត្តឲ្យកើតសេចក្តីស្វាហាប់ជានិរន្តរ ទើប ឈ្មោះថាជាមនុស្សមានគំនិតជាសប្បុរស អ្នកប្រាជ្ញលោកមិនដែលសរ-សើរមនុស្សដ៏កៀវក្រាខុសទំនងឡើយ ។

មិត្តកថា គួរសាធុជនទាំងធ្វើសេចក្តីសាមគ្គីព្រមព្រៀងគ្នា រាប់អាន យកគ្នាជាមិត្តមេត្រី ដើម្បីចៀសវាងកិរិយាអាក្រក់គ្រប់យ៉ាង ទុកជា នៅស្រុកទេសឆ្ងាយពីគ្នា ផ្សេងដោយជាតិគោត្រត្រកូល ទីលំនៅ របរកស៊ីក៏ដោយ ទោះមិនដែលបានជួយធុរៈកិច្ចការគ្នាក៏ដោយ វេលា ដែលបាននៅជាមួយគ្នា ឬបានជួបប្រទះគ្នាក្នុងទីណាផ្សេងៗ ត្រូវធ្វើ សេចក្តីល្អឲ្យប្រាកដ សមភាពជាមនុស្សជាតិមិនត្រូវសំដែងរិទ្ធិឬអំណាច កោងកាចដល់គ្នាឡើយ ។

គួរស្គាល់ឲ្យជាក់ច្បាស់ ចំពោះកិរិយារបស់ដែលមិនមែនជាមិត្ត សំឡាញ់ ព្រោះមនុស្សមិនមែនជាមិត្តរមែងធ្វើសេចក្តីភ័យឲ្យកើតឡើង ដល់រូបបុរសស្ត្រីក្នុងពិភពលោកនេះ ។ ឯកិរិយានោះគួរស្គាល់ថា បុគ្គលជាសត្រូវនឹងគ្នា កាលបើក្រឡេកឃើញគ្នាកាលណា ក៏ចង់ចំពោម

បើកភ្នែកសំឡក់សំឡឹងប្រឹងដំឡើងមុខធ្វើក្រញូវ មិនធ្វើសេចក្ដីត្រេកអរសាទរនឹងគ្នា មិនមើលឲ្យចំមុខប្រទះប៉ះភ្នែកគ្នាឡើយ តែងដំឡើងឫកពាទឹងឃោរឃៅចំពោះគ្នាជាដរាប នេះជាដំណើរកិរិយារបស់បុគ្គលមិនមែនជាមិត្ត ៗ ដូចគ្នានឹងសត្វសុនខ ក៏ធម្មតាសត្វសុនខ តែឃើញគ្នាហើយ ពុំដែលមានសេចក្ដីសោមនស្សរីករាយត្រេកអររាប់រកគ្នាទេ តែងសំដែងអាការកំហឹងប្រឹងបញ្ចេញធ្មេញបង្ហាញចង្កូមដើម្បីឫទ្ធិអំណាចរបស់វា នេះជាកិរិយារបស់សត្វឆ្កែ ៗ

ក៏ក្នុងមិត្តបាយន: ការណ៍ដែលនាំឲ្យបែកមិត្តពីគ្នា នាំមិនឲ្យស្រឡាញ់រាប់រកគ្នានោះ លោកសំដែងថា:

សព្វាភិក្ខណសំសគ្គា អសមោសរណេន ច
ឯតេន មិត្តា ជីរន្តិ អកាលេ យាចនេន ច...

មិត្តសំឡាញ់ណាដែលគេរៀនឆ្កឹះឆ្កៀលគ្នាទៅវិញទៅមកឥតអធ្យាស្រ័យហួសប្រមាណ ១, មិត្តសំឡាញ់ណាដែលឃ្លាតឃ្លាបែកចាកគ្នា ជាយូរយារមិនបានជួបមុខគ្នា ១, មិត្តសំឡាញ់ណាដែលសូមរបស់អ្វីៗញឹកញយ ក្នុងកាលដែលមិនគួរសូម ១, ហេតុទាំង ៣ យ៉ាងនេះកើតឡើងជាញឹកញយ មនុស្សទាំងឡាយតែងបែកបាក់ចាកគ្នា មិនបានជាមិត្តសំឡាញ់តយូរអង្វែងឡើយ ៗ ហេតុនេះមនុស្សដែលបានយកគ្នាជាសម្ពន្ធ-មិត្តមេត្រីហើយ គួរគប្បីចៀសវាងហេតុដែលនាំឲ្យជាទំនាស់បែកបាក់មិត្ត

នោះចេញ ហើយត្រូវប្រព្រឹត្តកាន់ចរិយាការចងសម្ពន្ធមិត្តឲ្យបានយូរអង្វែងលែងបែកបាក់គ្នានោះៗ ទៅតាមលំអានពុទ្ធភាសិតថា:

តស្មា អាភិក្ខណំ គច្ឆេ ន ច គច្ឆេ ចិរាចិរំ

កាលេន យាចំ យាចេយ្យ ឯវំ មិត្តា ន ជិយ្យរេ ។

សេចក្ដីថា មនុស្សដែលបានចងគ្នាជាមិត្តកួបកាន់ចិត្តស្រឡាញ់កប់រគ្នាដោយមេត្រីហើយ មិនគួរតែបៀតទៅមករកគ្នារឿយៗឡើយ យូរៗសឹមទៅម្ដង ពាក្យចំនៀមថា «ស្រឡាញ់កុំទៅញឹកៗ កាលណារលឹកសឹមទៅម្ដងៗ»: មែនពិត តែថាមិនគួរបោលគ្នាឲ្យឃ្លាតឃ្លាយូរពេកដែរ គោងតែយូរៗ ទៅមករកគ្នាម្ដងទើបគួរ បើសូមរបស់អ្វីដែលគួរសូម ត្រូវសូមគ្នាតាមកាលដែលគួរសូម យ៉ាងនេះបានឈ្មោះថា សម្ពន្ធមិត្តចងចិត្តមេត្រីល្អ ទើបមិនបែកបាក់គ្នាឡើយ ។

មួយទៀត, ការដែលសង្កេតគម្ពលក្ខណៈរបស់មិត្តសំឡាញ់ឲ្យឃើញជាក់ច្បាស់ រូបសឹមសេពគប់ស្និទ្ធស្នាលយកជាគៀននោះ បានដោយកម្រពេកណាស់ មិនងាយនឹងស្គាល់បាន តែលោកបានពោលទុកថា:

អហិតេ បដិសេធោ ច ហិតេសុ ច និយោជកោ

ព្យសនេ ចាបរិច្ចាគោ សង្ខេបំ មិត្តលក្ខណំ ។

មិត្តសំឡាញ់ណាហាមឃាត់គ្នាក្នុងកម្មមិនជាប្រយោជន៍ មិត្តសំឡាញ់ណាដឹកនាំគ្នាឲ្យប្រកបក្នុងកម្មជាប្រយោជន៍ មិត្តសំឡាញ់ណាមិន

លះបង់ពេលគ្នាក្នុងគ្រាដែលមានវិបត្តិ   អាចគានាជួយជ្រោងគ្នាឲ្យបានដំកល់នៅក្នុងឋានៈយសសក្តិស្មើមុខគ្នាដូចដើម   មិត្តសំឡាញ់បែបនោះឯង   បុគ្គលត្រូវយកធ្វើជាមិត្តសំឡាញ់ចុះ   ដែលលោកអ្នកប្រាជ្ញកំណត់ថាជាមហាមិត្តដ៏ប្រសើរ ។

ជនណាដែលមិនមែនជាញាតិសាច់សាលោហិតរបស់ខ្លួនទេ តែគេបានប្រកបប្រយោជន៍ដ៏ល្អចំពោះខ្លួន   គេបានរួបរួមសេចក្តីសុខទុក្ខជាមួយនឹងខ្លួន   ជននោះឈ្មោះថាជាមិត្តទុកស្មើដោយញាតិសាច់សាលោហិតផៅពង្សរបស់ខ្លួនពិត,   មិត្តណាមិនមានសេចក្តីឫស្យាប្រណែនគ្នាទេ គេបេះប៉ាច់ចិញ្ចឹមរក្សាខ្លួនល្អ មិត្តនោះលោកឲ្យឈ្មោះថា ជាឪពុកម្តាយរបស់ខ្លួនពិត,   ស្ត្រីណាជាមិត្តស្នេហាក្នុងផ្ទះអាចរំលត់សេចក្តីទុក្ខសោកគ្រប់ពេលបាន   ស្ត្រីនោះលោកឲ្យឈ្មោះថាភរិយាសុខសួស្តី ។

ភរិយាកាចមានចិត្តប្រទុស្តក្បត់ចិត្តស្វាមីរបស់ខ្លួនក្តី   មិត្តសំឡាញ់កាចមានចិត្តប្រទុស្តមិត្តផងគ្នាក្តី   ខ្ញុំធំជាងម្ចាស់ក្តី   បុគ្គលជាសប្បុរសត្រូវបៀសវាងវៀរលែងឲ្យស្រឡះ   កុំទៅសេពគប់យកជាគ្នា   នឹងមានទុក្ខព្រួយលំបាកដល់ខ្លួនពុំខានឡើយ   ដូចគ្នានឹងមនុស្សនៅក្នុងផ្ទះ   ដែលមានពស់វែកនៅអាស្រ័យជាមួយផង   នឹងមានតែសេចក្តីស្លាប់តែម្យ៉ាងប៉ុណ្ណោះកុំសង្ស័យឡើយ ។

ន័យខ្លះលោកបានសំដែងថា:

ន វិស្សាសេ អមិត្តស្ស មិត្តស្សាបិ ន វិស្សាសេ
កទាចិ កុប្បិតោ មិត្តោ សព្វទោសំ បកាសយេ ។

បុគ្គលជាសប្បុរសមិនគប្បីស្និទ្ធស្នាលរាប់រកនឹងពួកជនជាអសប្បុរស ដែលមិនមែនជាមិត្តល្អ គឺមិត្តណាដែលប្រកាសប្រាប់ទោសទាំងពួងរបស់មិត្តដល់ជនដទៃក្នុងពេលដែលខឹង មិត្តនោះ បុគ្គលជាសប្បុរសមិនត្រូវស្និទ្ធស្នាលរាប់រកឡើយ ។

មិត្តសំឡាញ់ណាដែលមានប្រាជ្ញាល្អ ទោះបីខ្លួនដល់សេចក្តីព្រួយទុក្ខលំបាកដោយខ្លួនឯងយ៉ាងណា ក៏មិនត្អូញត្អែរប្រាប់មិត្ត មិនកុហកបញ្ឆោតប្រាប់មិត្តផង មិនមើលងាយមិត្ត មិត្តយ៉ាងនេះ បុគ្គលជាសប្បុរសគប្បីសេពគប់យកជាមិត្តស្និទ្ធស្នាលឲ្យមាំទាំចុះ នឹងបានសេចក្តីចំរើនប្រយោជន៍គ្រប់យ៉ាង ។

ន័យមួយទៀតថា: ការសេពគប់មិត្តដែលគួរនឹងសេពគប់មាន ១០ ពួកលោកពោលទុកថា :

ពុទ្ធា បច្ចេកពុទ្ធា ច អរហន្តា ពុទ្ធសាវកា
មាតាបិតុគរុកាតា ទាយកា ធម្មទេសកា
មិត្តំ ទសវិធំ លោកេ ភជិតព្វំ នយញ្ញុនា ។

សេចក្តីថា: បុគ្គលជាអ្នកប្រាជ្ញមានប្រាជ្ញាដឹងនូវន័យ គប្បីសេពគប់នូវមិត្ត ១០ យ៉ាងគឺ ព្រះសម្ពុទ្ធជាម្ចាស់ ១, ព្រះបច្ចេកពុទ្ធ ១, ព្រះអរហន្តទាំងឡាយ ១, សាវករបស់ព្រះសម្ពុទ្ធជាម្ចាស់ ១, មាតា ១, បិតា ១, គ្រូអាចារ្យ ១, បងប្រុស-ស្រី ១, ទាយកអ្នកឲ្យទាន ១, បុគ្គលអ្នកសំដែងធម៌ ១, បុគ្គលទាំងនេះលោកហៅថា មហាមិត្តដ៏ប្រសើរក្នុងលោក ។

មេត្តិភាវញ្ច ភាវេយ្យ ភាគវេធិញ្ច ភាវេយ្យ
ភាវេយ្យ ភាវតំ បូជំ តេសុ ឧសរំផេសុបំ
ជិន្នភត្តំ យថា សារំ បរត្ថ សុខទាយកំ ។

បុគ្គលគួរធ្វើនូវភាពរបស់ខ្លួនឲ្យជាមិត្តមេត្រីផង គួរធ្វើនូវកតវេទិតាធម៌ផង គួរធ្វើនូវកិរិយាបូជាចំពោះមហាមិត្តទាំង ១០ ពួកនេះផង ផលានិសង្សដែលខ្លួនបានធ្វើបានបូជានោះៗ លោកទុកដូចជាកំណប់ទ្រព្យដ៏មានខ្លឹម រមែងឲ្យផលគឺសេចក្តីសុខចំរើន ទាំងនាលោកនេះនិងលោកខាងមុខដោយពិត ។

សកឹ ទុដ្ឋំ ប៉ិយំ មិត្តំ បុន សន្ធាតុមិច្ឆតិ
សោ មច្ចុមុបគណ្ហាតិ គព្ភោ អស្សតរី យថា ។

បុគ្គលប្រាជ្ញាទំនុកបំរុងទ្រទ្រង់មិត្តសំឡាញ់ឯណា បើកប្រទុស្ត-កាយអស់ការៈម្តងហើយ នឹងយកកជាមិត្តសំឡាញ់ទៀត (ពុំបានឡើយ)

មិត្តសំឡាញ់នោះ រមែងនាំខ្លួនឲ្យចូលទៅកាន់សេចក្ដីស្លាប់ជាពិតប្រាកដ ដូចគ្នានឹងគតិនៃមេសេះអស្សតរ រមែងសម្លាប់មេក (ជាទំនៀម) ។

ក្នុងទីបំផុតនៃមិត្តកថានេះ សូមនាំយករឿង ១ មកជាឧទាហរណ៍ ដើម្បីនឹងសរសេចក្ដីនៃមិត្តកថា ឲ្យឃើញជាក់ច្បាស់ត្រង់មិត្តសំឡាញ់ ដែលជាដឹកនាំឲ្យបានសេចក្ដីសុខ-ចំរើន ដរាបដល់ឡើងថ្នាក់ទៅជាមហាមិត្តដ៏ប្រសើរ ។

សេចក្ដីថា: កាលព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើង សោយព្រះជាតិជាជោតិបាលមាណព ក្នុងសាសនាព្រះពុទ្ធទ្រង់ព្រះនាមកស្សប-សម្មាសម្ពុទ្ធជាម្ចាស់ ។

គ្រានោះ មានឃដិការស្មូនឆ្នាំងម្នាក់ជាមិត្តសំឡាញ់ បាននិយាយបបួលជោតិបាលមាណព ៣ ដង ឲ្យចូលទៅគាល់ព្រះពុទ្ធកស្សបជាព្រះអរហន្តសម្មាសម្ពុទ្ធ, ឯជោតិបាលមាណព ក៏ឃាត់ឃដិការស្មូនឆ្នាំង ៣ ដងថា: កុំឡើយសំឡាញ់ ចុះឯងចូលទៅគាល់ស្រមណ៍កំណាក្រនោះ បានជាការអ្វី! ប្រកែកមិនព្រមទៅ ទាល់តែឃដិការស្មូនឆ្នាំងចាប់ទាញឆ្នក់ទាញសក់ក្បាលកំពុងងូតទឹករួច ទើបកន្ត្រាក់ចូលទៅគាល់ព្រះពុទ្ធ-កស្សបទាល់តែបាន ហើយសូមឲ្យព្រះអង្គសំដែងធម៌ប្រោសជោតិបាល-មាណពឲ្យជឿជាក់រីករាយដោយធម្មកថារបស់ព្រះអង្គ ។

ឯជោតិបាលមាណព ក៏លះបង់យកកាសចូលទៅបួសក្នុងសំណាក់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។ ឃដិការស្មូនឆ្នាំងនេះ មិនត្រឹមតែមានមិត្តសំឡាញ់នឹងជោតិបាលមាណពជាយកកាសជួបគ្នាទេ សូម្បីតែព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សប ព្រះអង្គក៏ទំនុកទុកចិត្តស្និទ្ធស្នាលហាក់ដូចជាមិត្តសំឡាញ់ដែរ, ដូចកាលដែលគាត់មិននៅផ្ទះទៅធ្វើការផ្សេងៗ ទ្រង់ហ៊ានយាងទៅយកបាយអំពីឆ្នាំង យកសម្លអំពីកាជន យកនំកុម្មាសអំពីកឡេទៅឆាន់ ។

ថ្ងៃក្រោយទ្រង់ចាត់ឲ្យភិក្ខុទាំងឡាយទៅរុះស្បូវ ដែលប្រក់ផ្ទះរបស់គាត់យកមកប្រក់កុដិរបស់ព្រះអង្គ ដែលលេចភ្លៀង, ទុកចំហផ្ទះនោះចោលទទេ យកអាកាសជាគ្រឿងប្រក់ដរាបអស់ ៣ ខែ ប៉ុន្តែមិនលេចភ្លៀងទេ ។

ឃដិការស្មូនឆ្នាំងមានសេចក្ដីសុខកាយសប្បាយចិត្ត ដែលកើតអំពីបីតិអស់កន្លះខែ ដោយសេចក្ដីពេញចិត្តនឹកថា ព្រះពុទ្ធលោកស្និទ្ធស្នាលនឹងអញពេកណាស់; មនុស្សដូចជាឃដិការស្មូនឆ្នាំងនេះបានឈ្មោះថា មហាមិត្តចិត្តត្រង់ ដឹកនាំសំឡាញ់ផងគ្នាឲ្យបានសម្រេចប្រយោជន៍ដូចជាខ្លួនដែរ គួរសាធុជនទាំងឡាយចំដឹកនាំគ្នាឲ្យបានសម្រេចប្រយោជន៍ត្រៃយ៉ាងចុះ ។ ឃដិ សម្ពុតា ទេសនា ។

ធម្មទេសនា សន្តិបាតចប់តែប៉ុណ្ណេះ ។